**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខ: ៤១ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា

-បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០០០ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងលើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់

-បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

-បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

-បានឃើញអនុក្រឹត្យលេខ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា

-បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១០

# សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីយន្តការ នីតិវិធីនិងលក្ខខណ្ឌនៃការជ្រើសរើស និងការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលបំណងដូចតទៅៈ

-លើកកម្ពស់គុណភាពបណ្តុះបណ្តាល នៃគ្រឹះស្ថានឧត្តមសិក្សាក្នុងវិស័យសុខាភិបាល

-លើកតម្កើងកិត្តិយស និងសេចក្តីថ្លៃថ្នូរបស់សាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល

-ចូលរួមចំណែករៀបចំ និងអភិវឌ្ឍធនធានមនុស្ស ក្នុងវិស័យសុខាភិបាលឲ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់

-លើកកម្ពស់ការទទួលខុសត្រូវរបស់សាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល

-បង្កើនកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុង និងក្រៅប្រទេសក្នុងការបណ្តុះបណ្តាលធនធានមនុស្ស។

**មាត្រា៣.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសាស្ត្រាចារ្យជំនួយ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

# ជំពូកទី២
# ក្រុមប្រឹក្សាជាតិត្រួតពិនិត្យ ការផ្តល់ឋានៈ សាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល

**មាត្រា៤.-**

ត្រូវបានបង្កើតក្រុមប្រឹក្សាជាតិ ត្រួតពិនិត្យការផ្តល់ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល សរសេរកាត់ថា **ក.ត.ស.ស.** ដែលមានសមាសភាពមកពី ៖

- -តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ១រូប
- -តំណាងក្រសួងសុខាភិបាល ១រូប
- -តំណាងក្រសួងអប់រំ យុវជន និងកីឡា ១រូប
- -តំណាងសាស្ត្រាចារ្យវិស័យសុខាភិបាល ៨រូប។

សមាសភាព **ក.ត.ស.ស.** មានអាណត្តិ ៣(បី) ឆ្នាំ ហើយអាចបន្តអាណត្តិរបស់ខ្លួនសាជាថ្មីទៀត។

សមាសភាពដែលជាតំណាងសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល ត្រូវជ្រើសរើសដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល។

សមាសភាពជាក់ស្តែងនៃ **ក.ត.ស.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៥.-**

**ក.ត.ស.ស.** មានតួនាទី និងភារកិច្ចដូចតទៅ៖

- -អនុម័ត និងកែសម្រួលបទបញ្ជាផ្ទៃក្នុងរបស់ **ក.ត.ស.ស.**
- -កំណត់បែបបទស្តីពីការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- -អនុម័តយល់ព្រមលើសមាសភាពគណៈមេប្រយោគសម្រាប់វាយតម្លៃសាស្ត្រាចារ្យ
- -អនុម័តយល់ព្រមលើលទ្ធផល នៃការវាយតម្លៃរបស់គណៈមេប្រយោគ
- -រៀបចំ និងអនុម័តគម្រោងថវិកា សម្រាប់ដំណើរការប្រឡងជ្រើសរើសសាស្ត្រាចារ្យ
- -ទទួល និងដោះស្រាយបណ្តឹងតវ៉ារបស់គណៈមេប្រយោគ ឬបេក្ខជន
- -បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល។

**មាត្រា៦.-**

សមាជិក **ក.ត.ស.ស.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។

**មាត្រា៧.-**

**ក.ត.ស.ស.** ត្រូវប្រជុំយ៉ាងតិច២(ពីរ)ដង ក្នុង១(មួយ)ឆ្នាំ។

ការប្រព្រឹត្តទៅនៃអង្គប្រជុំ និងរបៀបរបបការងាររបស់ **ក.ត.ស.ស.** ត្រូវកំណត់ក្នុងបទបញ្ជាផ្ទៃក្នុងរបស់ **ក.ត.ស.ស.**។

**មាត្រា៨.-**

ក.ត.ស.ស.មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ឬទីប្រឹក្សា ដើម្បីចូលរួមប្រជុំតាមការចាំបាច់។

ក.ត.ស.ស. អាចទទួលយកទីប្រឹក្សាបច្ចេកទេស អ្នកជំនាញការជាតិ ឬអន្តរជាតិនានាមួយចំនួនតាមការចាំបាច់។

**មាត្រា៩.-**

ក.ត.ស.ស. មាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស នៃក្រសួងសុខាភិបាល ជាលេខាធិការដ្ឋាន។

លេខាធិការដ្ឋាន ក.ត.ស.ស. មានមន្ត្រីបម្រើការងារមកពី ក្របខណ្ឌក្រសួងសុខាភិបាល ទីស្តីការគណៈរដ្ឋមន្ត្រី និងមកពីក្របខណ្ឌមុខងារសាធារណៈផ្សេងទៀត ។

**មាត្រា១០.-**

ក.ត.ស.ស. មានប្រភពធនធានមកពី ៖

-ថវិកាជាតិ ដែលជាកញ្ចប់ថវិការបស់ក្រសួងសុខាភិបាល

-ថវិកាដែលបានមកពីការដាក់ពាក្យប្រឡងរបស់បេក្ខជន និង

-ប្រភពផ្សេងៗទៀត។

**មាត្រា១១.-**

ក.ត.ស.ស. មានសិទ្ធិប្រើប្រាស់ត្រាដោយឡែក ដើម្បីដំណើរការការងាររបស់ខ្លួន។

## ជំពូកទី៣

## ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល និងគុណវុឌ្ឍិសម្រាប់ការប្រឡងជ្រើសរើស

**មាត្រា១២.-**

ឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាល ត្រូវបានកំណត់ដូចខាងក្រោម៖

-សាស្ត្រាចារ្យជំនួយ

-សាស្ត្រាចារ្យរង និង

- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ។

**មាត្រា១៣.-**

បេក្ខជនដែលអាចប្រឡងជ្រើសរើសជាសាស្ត្រាចារ្យ ទៅតាមកម្រិតនីមួយៗ ដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះបាន ត្រូវមានគុណវុឌ្ឍិដូចខាងក្រោម៖

ក-សាស្ត្រាចារ្យជំនួយ

-មានសញ្ញាបត្រឯកទេសថ្នាក់ក្រោយបរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា

-មាននិក្ខេបបទវិជ្ជាជីវៈ ឬនិក្ខេបបទស្រាវជ្រាវ

-មានអត្ថបទស្រាវជ្រាវយ៉ាងតិច ៣(បី)ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីក្នុងស្រុក ឬក្នុងតំបន់ ឬបានដឹកនាំនិក្ខេបបទយ៉ាងតិចចំនួន៥(ប្រាំ)

-បាននិងកំពុងធ្វើការយ៉ាងតិច៦(ប្រាំមួយ)ឆ្នាំ នៅគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ឬមន្ទីរពេទ្យ ឬអង្គភាពស្រាវជ្រាវវេជ្ជសាស្ត្រ និងឱសថសាស្ត្រនានា ដែលទទួលស្គាល់ដោយក្រសួងសុខាភិបាល

-ជាគ្រូបង្រៀនទ្រឹស្តីយ៉ាងតិច ៣(បី) ឆ្នាំ ឬជាគ្រូណែនាំគ្លីនីក ឬជាគ្រូណែនាំអនុវត្តយ៉ាងតិច ៦ (ប្រាំមួយ)ឆ្នាំ ឬបានឆ្លងកាត់វគ្គបណ្តុះបណ្តាលគរុកោសល្យវិស័យសុខាភិបាល រយៈពេលចាប់ពី១២(ដប់ពីរ)ខែឡើងទៅ

-ជាសមាជិកគណៈវិជ្ជាជីវៈ

-មិនធ្លាប់មានកំហុសវិជ្ជាជីវៈ និងមិនធ្លាប់ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ។

ខ-សាស្ត្រាចារ្យរង

-បានបម្រើការងារជាសាស្ត្រាចារ្យជំនួយយ៉ាងតិច៥(ប្រាំ)ឆ្នាំ

-មានអត្ថបទស្រាវជ្រាវដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ។

គ- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ

-បានបម្រើការងារជាសាស្ត្រាចារ្យរងយ៉ាងតិច ៥(ប្រាំ)ឆ្នាំ

-មានអត្ថបទស្រាវជ្រាវយ៉ាងតិច៣(បី)ដែលបានផ្សព្វផ្សាយក្នុងទស្សនាវដ្ដីវិទ្យាសាស្ត្រអន្តរជាតិ។

## ជំពូកទី៤
## នីតិវិធីនៃការជ្រើសរើស
### ផ្នែកទី១
### នីតិវិធីនៃការជ្រើសរើសគណៈមេប្រយោគ

**មាត្រា១៤.-**

សាកលវិទ្យាធិការនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគមួយដែលរៀបចំឡើងដោយគណៈកម្មាធិការបច្ចេកទេសនៃគ្រឹះស្ថានរបស់ខ្លួន យោងតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ ទៅ **ក.ត.ស.ស.** ដើម្បីសុំការអនុម័តយល់ព្រម។ **ក.ត.ស.ស.** ត្រូវផ្តល់ការយល់ព្រម ឬបដិសេធលើសមាសភាពគណៈមេប្រយោគក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការ។ ក្នុងករណីបដិសេធ **ក.ត.ស.ស.** ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរអំពីមូលហេតុនៃការបដិសេធទៅសាកលវិទ្យាធិការនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលពាក់ព័ន្ធ ដើម្បីធ្វើការរៀបចំសមាសភាពជាថ្មីឡើងវិញ។

បន្ទាប់ពីទទួលបានការយល់ព្រមលើសមាសភាពគណៈមេប្រយោគ សាកលវិទ្យាធិការនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលពាក់ព័ន្ធ ត្រូវបញ្ជូនបញ្ជីសមាសភាពគណៈមេប្រយោគនេះទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល ដើម្បីធ្វើការតែងតាំង។

**មាត្រា១៥.-**

គណៈមេប្រយោគដែលទទួលបានការតែងតាំង មានឆន្ទានុសិទ្ធិក្នុងការវាយតម្លៃលើបេក្ខជន ដើម្បីទទួលបានឋានៈសាស្ត្រាចារ្យណាមួយ។

**មាត្រា១៦.-**

សមាសភាពគណៈមេប្រយោគ សម្រាប់ការប្រឡងជ្រើសរើសសាស្ត្រាចារ្យ ត្រូវមានដូចខាងក្រោម៖

ក-សាស្ត្រាចារ្យជំនួយ

សមាសភាពគណៈមេប្រយោគមានចំនួន ៧(ប្រាំពីរ)រូប ដូចខាងក្រោម៖

-សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងនិងមានអតីតភាពយូរជាងគេជាប្រធាន

-សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យជំនួយជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យក្នុងឋានៈណាមួយមកពីដេប៉ាតឺម៉ង់នៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន ។

ខ-សាស្ត្រាចារ្យរង

សមាសភាពគណៈមេប្រយោគមានចំនួន៧(ប្រាំពីរ)រូបដូចខាងក្រោម៖

- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ដែលមានអតីតភាពយូរជាងគេជាប្រធាន

-សាស្ត្រាចារ្យដែលមានឋានៈចាប់ពីសាស្ត្រាចារ្យរងជាសមាជិក ដែលក្នុងនោះត្រូវមានសាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ឬសាស្ត្រាចារ្យរងមកពីដេប៉ាតឺម៉ង់នៃមុខវិជ្ជាដែលបេក្ខជនទទួលបន្ទុកបង្រៀន។

គ- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ

សមាសភាពគណៈមេប្រយោគមានចំនួន ៥(ប្រាំ)រូបដូចខាងក្រោម៖

- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ដែលមានអតីតភាពយូរជាងគេជាប្រធាន

- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ចំនួន២(ពីរ)រូបជាសមាជិក

- សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ដែលអញ្ជើញមកពីគ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាលដទៃទៀត ឬ សាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យបរទេសចំនួន២(ពីរ)រូប ជាសមាជិក។

## ផ្នែកទី២
## នីតិវិធីនៃការជ្រើសរើសសាស្ត្រាចារ្យ និងការផ្តល់ឋានៈ

**មាត្រា១៧.-**

ចំនួនសាស្ត្រាចារ្យគ្រប់កម្រិតរបស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗក្នុងវិស័យសុខាភិបាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១៨.-**

បេក្ខជនដែលមានបំណងប្រឡងដើម្បីទទួលបានឋានៈសាស្ត្រាចារ្យក្នុងវិស័យសុខាភិបាលដូចមានចែងក្នុងមាត្រា១២ នៃអនុក្រឹត្យនេះ ត្រូវដាក់ពាក្យស្នើសុំទៅសាកលវិទ្យាល័យ នៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ដោយភ្ជាប់មកជាមួយនូវ៖

-ពាក្យស្នើសុំប្រឡងជ្រើសរើស
-ច្បាប់ចម្លងសញ្ញាបត្រវិជ្ជាជីវៈ ឬសញ្ញាបត្រវិជ្ជាជីវៈ
-ផែនការអភិវឌ្ឍវិជ្ជាជីវៈរបស់បេក្ខជនសម្រាប់ទ្រទ្រង់ការអភិវឌ្ឍការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
-លិខិតបញ្ជាក់សមាជិកភាពរបស់គណៈវិជ្ជាជីវៈ
-លិខិតថ្កោលទោស
-ឯកសារផ្សេងៗទៀតតាមការចាំបាច់។

គំរូពាក្យស្នើសុំសម្រាប់ការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.ត.ស.ស.**។

**មាត្រា១៩.-**

បែបបទនៃការប្រឡងជ្រើសរើស ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.ត.ស.ស.**។

**មាត្រា២០.-**

សាកលវិទ្យាធិការនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល ត្រូវបញ្ជូនលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគមក **ក.ត.ស.ស.** ដើម្បីសុំការយល់ព្រម។ រាល់ការជំទាស់ណាមួយរបស់ **ក.ត.ស.ស.** ត្រូវមានការបញ្ជាក់ឲ្យបានច្បាស់អំពីមូលហេតុនៃការជំទាស់។

ក្នុងករណីមានវិការៈខាងទម្រង់ណាមួយ ក្នុងនីតិវិធីនៃការជ្រើសរើសដែលអាចធ្វើនិយ័តកម្មបាន **ក.ត.ស.ស.** ត្រូវធ្វើការបញ្ជាក់ឲ្យបានច្បាស់លាស់ ដោយតម្រូវឲ្យគណៈមេប្រយោគកែតម្រូវឡើងវិញ។

បេក្ខជនដែលមិនសុខចិត្តនឹងលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ មានសិទ្ធិប្តឹងតវ៉ាទៅ **ក.ត.ស.ស.** ដើម្បីស្នើសុំពិនិត្យឡើងវិញ។ ក្នុងការពិនិត្យលើបណ្តឹងតវ៉ានេះ **ក.ត.ស.ស.** ត្រូវគោរពតាមអំណាចឆន្ទានុសិទ្ធិរបស់គណៈមេប្រយោគដែលមានចែងក្នុងមាត្រា១៥នៃអនុក្រឹត្យនេះ។

នីតិវិធីនៃការដោះស្រាយបណ្តឹងតវ៉ារបស់បេក្ខជន ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ **ក.ត.ស.ស.**។

**មាត្រា២១.-**

បន្ទាប់ពីទទួលបានការយល់ព្រមពី គ.គ.ស.ស. លើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ និង មិនមានការប្តឹងតវ៉ាណាមួយ លើលទ្ធផលនៃការវាយតម្លៃរបស់គណៈមេប្រយោគ សាកលវិទ្យាធិការនៃគ្រឹះស្ថាន បណ្តុះបណ្តាលវិស័យសុខាភិបាលពាក់ព័ន្ធ ត្រូវបញ្ជូនលទ្ធផលប្រឡងរបស់បេក្ខជនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល រៀបចំការតែងតាំង។

ការផ្តល់ឋានៈជាសាស្ត្រាចារ្យជំនួយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

ការផ្តល់ឋានៈជាសាស្ត្រាចារ្យរង ត្រូវកំណត់ដោយអនុក្រឹត្យ។

ការផ្តល់ឋានៈជាសាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ត្រូវកំណត់ដោយព្រះរាជក្រឹត្យ។

## ជំពូកទី៥
## បន្ទុកការងាររបស់សាស្ត្រាចារ្យ

**មាត្រា២២. -**

បន្ទុកការងាររបស់សាស្ត្រាចារ្យតាមកម្រិតនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា២៣. -**

សាស្ត្រាចារ្យមហាបរិញ្ញា ដែលបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលកន្លងមក នៅរក្សាឋានៈជាសាស្ត្រាចារ្យមហាបរិញ្ញាដដែល។

សាស្ត្រាចារ្យមហាបរិញ្ញា ដែលបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលកន្លងមក ហើយមានបំណងស្នើសុំការតែងតាំងសាជាថ្មីដោយព្រះរាជក្រឹត្យ ត្រូវបំពេញតាមលក្ខខណ្ឌដូចមានចែងក្នុង អនុក្រឹត្យនេះ។

ក្រោយពេលអនុក្រឹត្យនេះចូលជាធរមាន រាល់ការតែងតាំងសាស្ត្រាចារ្យមហាបរិញ្ញា/សាស្ត្រាចារ្យ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវហាមឃាត់។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា២៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ២០១០

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា២៥
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ